សុន្ទរកថាបើកកម្មវិធី

របស់ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្នុងពិធីប្រារព្ធខួបឆ្នាំទី ៥០ នៃការបង្កើត ADB

វេទិកាពិភាក្សាកម្រិតជាន់ខ្ពស់ស្តីពី

"ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការអភិវឌ្ឍនៅកម្ពុជា"

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៦

- *ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ជូនចំពោះឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់*
- *លោកស្រី Noriko Ogawa អគ្គនាយករងធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបន្ទុកតំបន់អាស៊ីភាគអាគ្នេយ៍*
- *លោក Samiuela T. Tukuafu, នាយកស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា*
- *សហសេវិក នៃរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ជាទីមេត្រី !*

១- ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សឥតឧបមា ដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ក្នុងពិធីប្រារព្ធខួបឆ្នាំទី៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី[1]។ ជាបឋម ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមអនុញ្ញាតសម្តែងនូវគារវកិច្ចស្វាគមន៍ និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ព្រមទាំងវាគ្មិនទាំងអស់ និងមន្ត្រីគ្រប់ជាន់ថ្នាក់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានចូលរួមនៅក្នុងវេទិកាពិភាក្សាកម្រិតខ្ពស់ ស្តីពី "**ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការអភិវឌ្ឍនៅកម្ពុជា**"។ ទន្ទឹមនឹងវេទិកាពិភាក្សាកម្រិតខ្ពស់នេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ីក៏បានរៀបចំឲ្យមាន កម្មវិធីប្រកួតសំណេរអត្ថបទក្រោមប្រធានបទស្តីពី "**ការរួមចំណែករបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការអភិវឌ្ឍនៅកម្ពុជា និងវិស័យសម្រាប់កិច្ចសហប្រតិបត្តិការនាពេលអនាគត**" ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ខាងមុខនេះ។

២- ខ្ញុំក៏សូមសម្តែងនូវអំណរគុណដ៏ស្មោះស្ម័គ្រចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី តំណាងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍ទាំងអស់ អង្គការសង្គមស៊ីវិល និងដៃគូផ្នែកឯកជន ដែលបានអញ្ជើញចូលរួម និងបានញាំងឲ្យវេទិកាពិភាក្សាកម្រិតខ្ពស់នាពេលនេះ ប្រព្រឹត្តទៅប្រកបដោយបរិយាកាសអធិកអធម និងមានអត្ថន័យជ្រាលជ្រៅជាប្រវត្តិសាស្ត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ។

[1] ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦៦

៣- ការប្រារព្ធពិធីខួបឆ្នាំទី ៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ីនាថ្ងៃនេះ តាមរយៈវេទិកាពិភាក្សាកម្រិតខ្ពស់ គឺមានគោលបំណង (១) បង្ហាញឱ្យឃើញនូវសមិទ្ធផល ដែលសម្រេចបានមកពីកិច្ចសហប្រតិបត្តិការ ក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីកន្លងមក (២) ចែករំលែកនូវបទពិសោធន៍នៃការរួមចំណែករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា និង (៣) ផ្តល់នូវអនុសាសន៍សម្រាប់កិច្ចសហ-ប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីរយៈពេលវែងបន្តទៀត។

៤- ក្នុងឱកាសដ៏មហោឡារិកនេះ ខ្ញុំសូមអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី ចូលរួមជាមួយខ្ញុំ អបអរសាទរខួបឆ្នាំទី ៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី និង ភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ការអភិវឌ្ឍនៅកម្ពុជា!

៥- ក្នុងឱកាសដ៏ប្រពៃនេះ ខ្ញុំសូមគោរពអនុញ្ញាតជម្រាបអំពីសាវតារ និងសមិទ្ធិផលសម្រេចបានគួរឱ្យកត់សម្គាល់ នៃកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងរយៈពេល ៥០ ឆ្នាំកន្លងមក ដូចខាងក្រោម÷

៦- យើងមានមោទនភាពយ៉ាងខ្លាំងដែលព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកស្ថាបនិកមួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅឆ្នាំ១៩៦៦។ ក្នុងរយៈពេលកន្លះសតវត្សរ៍កន្លងមកនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានប្រែក្លាយខ្លួនពីធនាគារដែលមានប្រទេសជាសមាជិកចំនួន ៣១ នៅពេលកកើត មកជាធនាគារដែលមានប្រទេសជាសមាជិកចំនួន ៦៧ ក្នុងនោះ÷ ប្រទេសសមាជិកចំនួន ៤៨ មកពីក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក និងប្រទសសមាជិកចំនួន ១៩ មកពីក្រៅពីតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ យើងមានក្តីសោមនស្សជាអនេក ដែលបានធ្វើជាសាក្សីនៃការរីកធំធាត់នៃសមាជិកភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងបានចូលរួមបំពេញនូវរាល់កាតព្វកិច្ចទាំងឡាយ ដូចមានចែងក្នុងធម្មនុញ្ញនៃស្ថាប័ននេះ។

៧- ជាអកុសល នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបប្រល័យពូជសាសន៍ ប៉ុល ពត បានចូលមកគ្រប់គ្រងប្រទេស ដោយបានបំផ្លាញទាំងស្រុងនូវរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងនោះក៏មានទាំងប្រព័ន្ធធនាគារផងដែរ។ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៩១ គណនីសម្រាប់ធ្វើការទូទាត់បង់វិភាគទានសមាជិកភាពរបស់កម្ពុជាត្រូវបានបំផ្លាញ ហើយសមាជិកភាពរបស់កម្ពុជានៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ីក៏ត្រូវបានព្យួរ។ បន្ទាប់ពីសង្គ្រាមស៊ីវិលនៅកម្ពុជាត្រូវបានបញ្ចប់ ធនាគារអភិ-វឌ្ឍន៍អាស៊ីបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅកម្ពុជាឡើងវិញនៅឆ្នាំ១៩៩២ ហើយបន្ទាប់មក ស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា ក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៦ និងមានប្រតិបត្តិការពេញលេញចាប់ពីឆ្នាំ១៩៩៧ រហូតមកដល់បច្ចុប្បន្ន។

៨- បច្ចុប្បន្ន កម្ពុជាមានភាគហ៊ុនសរុបចំនួន ៥ ២៥០ ភាគហ៊ុន ដែលមានតម្លៃសរុបប្រមាណជាង ៧៣ លានដុល្លារអាមេរិកនៃដើមទុនសរុបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចំនួនប្រមាណ ១៤៧,០៥ ប៊ីលានដុល្លារអាមេរិក ដែលបែងចែកជា ១០ ៦០៣ ២១១ ភាគហ៊ុន។

៩- ចំពោះកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយកម្ពុជាពីឆ្នាំ១៩៩១ រហូតមកដល់ឆ្នាំ២០១៦ នេះ ធនាគារអភិវឌ្ឍន៍អាស៊ីគឺជាដៃគូអភិវឌ្ឍន៍ទីមួយ ដែលបានបញ្ជូនក្រុមបេសកកម្មរបស់ខ្លួន មកធ្វើការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍន៍របស់

កម្ពុជានៅក្នុងឆ្នាំ១៩៩១ គឺនៅក្នុងពេលដែលស្ថានភាពនៃការធ្វើដំណើរក្នុងប្រទេសនៅមានការលំបាកនៅឡើយ ដោយសារភាពខ្ទេចខ្ទាំនៃបណ្តាញផ្លូវគមនាគមន៍។ ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាដៃគូអភិវឌ្ឍន៍ពហុភាគីដ៏ធំជាងគេ ដែលបានរួមចំណែកយ៉ាងធំធេងក្នុងការជួយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា។ មកដល់ពេលនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់កម្ពុជាចំនួនប្រមាណ ២,៦៥ ប៊ីលានដុល្លារអាមេរិក[2] សម្រាប់កម្មវិធី និងគម្រោងអភិវឌ្ឍន៍ និងជំនួយបច្ចេកទេសសម្រាប់កសាងសមត្ថភាពស្ថាប័នរាជរដ្ឋាភិបាល។ ហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ ត្រូវបានប្រើប្រាស់សម្រាប់ការវិនិយោគសាធារណៈក្នុងវិស័យអាទិភាពមួយចំនួនដូចជា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវថ្នល់, ស្ពាន, ធារាសាស្ត្រ, កំពង់ផែ, ផ្លូវរថភ្លើង និងព្រលានយន្តហោះ), កសិកម្ម និងធនធានធម្មជាតិ, អប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, ថាមពល, ហិរញ្ញវត្ថុ, សុខាភិបាល និងការគាំពារសង្គម, ឧស្សាហកម្ម និងពាណិជ្ជកម្ម, ព័ត៌មានវិទ្យា និងកម្មវិធីកំណែទម្រង់ស៊ីជម្រៅលើវិស័យផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។ ចំណែកជំនួយបច្ចេកទេសក៏ត្រូវបានប្រើប្រាស់សម្រាប់កសាងសមត្ថភាពស្ថាប័នរាជរដ្ឋាភិបាលក្នុងការកសាងបទដ្ឋាន គតិយុត្ត, គោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ និងសមាហរណកម្មក្នុងតំបន់ ព្រមទាំងការសិក្សា និងកសាងគម្រោងអភិវឌ្ឍន៍នានាផងដែរ។

១០- ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសម្រាប់ឆ្នាំ២០១៧-២០១៩ ធនាគារអភិវឌ្ឍន៍អាស៊ីគ្រោងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបចំនួនប្រមាណ ១,០៩ ប៊ីលានដុល្លារអាមេរិក សម្រាប់អនុវត្តគម្រោង និងកម្មវិធីអភិវឌ្ឍន៍ នៅកម្ពុជា ក្នុងនោះរួមមាន ឥណទានសម្បទានចំនួនប្រមាណ ៨៧២ លានដុល្លារអាមេរិក និងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសចំនួន ១៣ លានដុល្លារអាមេរិក។ ហិរញ្ញប្បទានសហប្រតិបត្តិការខាងលើនេះ នឹងត្រូវប្រើប្រាស់សម្រាប់ការវិនិយោគសាធារណៈក្នុងវិស័យអាទិភាពមួយចំនួន ដូចជា÷ (១) កសិកម្ម ធនធានធម្មជាតិ និងអភិវឌ្ឍន៍ជនបទ, (២) អប់រំ, (៣) ដឹកជញ្ជូន, (៤) ទឹកស្អាត និងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មក្នុងទីក្រុង, (៥) ការគ្រប់គ្រងវិស័យសាធារណៈ, (៦) ហិរញ្ញវត្ថុ និង (៧) ពហុវិស័យ។ ទាំងនេះ បង្ហាញពីការប្តេជ្ញាបន្តពង្រឹងភាពជាដៃគូដ៏រឹងមាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជាមួយរាជរដ្ឋាភិបាលកម្ពុជា។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ពិតជាបានរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍនៅកម្ពុជា សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន តាមរយៈការបន្តធានាសម្រេចឱ្យបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។

១១- ដោយឡែក ចំពោះកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងតំបន់ដែលកម្ពុជាបានចូលរួម, ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តួចផ្តើមអនុវត្ត និងគាំទ្រដល់កម្មវិធីសហប្រតិបត្តិការជាច្រើន ដូចជា÷ កម្មវិធីនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងមហាអនុតំបន់មេគង្គ (GMS) និងការដាក់ឱ្យអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រមហាអនុតំបន់មេគង្គ ២០១២-២០២០ (GMS Strategic Framework 2012-2020) ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ធានានូវការអភិវឌ្ឍ, សមាហរណកម្ម និងសុខដុមនីយកម្មរបស់បណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ ក្នុងបរិការណ៍នៃសាកលភាវូបនីយកម្ម។ តាមរយៈ

[2] បើគិតហិរញ្ញប្បទានពីឆ្នាំ១៩៧០ ដល់ឆ្នាំ២០១៦ ប្រទេសកម្ពុជាទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការចំនួនប្រមាណ ២ ៦៥៧ លានដុល្លារអាមេរិក (គិតទាំងហិរញ្ញប្បទានដល់វិស័យឯកជន តែមិនបញ្ចូលសហហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត)

កិច្ចសហប្រតិបត្តិការក្នុងតំបន់នេះ កម្ពុជាបានកសាងនូវទំនាក់ទំនងដ៏ល្អជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ ជាពិសេសវិស័យផ្គត់ផ្គង់ថាមពល, ការគ្រប់គ្រងជម្ងឺឆ្លង និងទេសចរណ៍។ ទន្ទឹមនេះ កិច្ចសហប្រតិបត្តិការក្នុងតំបន់នេះក៏បានជួយកម្ពុជាក្នុងការពន្លឿននូវការដឹកជញ្ជូនទំនិញ និងការដោះដូរពាណិជ្ជកម្មឆ្លងកាត់ព្រំដែនផងដែរ។

១២- ជាការពិត, ធនាគារអភិវឌ្ឍន៍អាស៊ីគឺជាស្ថាប័នឈានមុខក្នុងការបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការក្នុងមហាអនុតំបន់មេគង្គ ដែលមិនត្រឹមតែបានផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងដល់បណ្តាប្រទេសជាសមាជិកក្នុងមហាអនុតំបន់មេគង្គប៉ុណ្ណោះទេ គឺថែមទាំងបានផ្តល់ប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការទាញយកផលចំណេញពីការអភិវឌ្ឍក្នុងមហាអនុតំបន់មេគង្គនេះទៀតផង។

១៣- សរុបមក ធនាគារអភិវឌ្ឍន៍អាស៊ី រួមជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត បានដើរតួនាទីដ៏ធំធេង ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាពក្នុងរយៈពេលវែង និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។ ខ្ញុំសូមកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានចូលរួមសម្រេចឲ្យបាននូវសមិទ្ធផលដ៏មានសារៈសំខាន់ទាំងនេះ។

១៤- យើងខ្ញុំក៏សូមសំដែងនូវកត្តញ្ញូតាធម៌ ចំពោះធនាគារអភិវឌ្ឍន៍អាស៊ីដែល យល់ពីបរិការណ៍នៃប្រទេសជាសមាជិកនីមួយៗ ហើយតែងបានឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងបញ្ហាប្រឈមដែលកើតមានឡើង ទាន់ពេលវេលា។ លើសពីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានចូលរួមជាមួយប្រទេសជាសមាជិកអាស៊ាន ក្នុងការបង្កើតមូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន (ASEAN Infrastructure Fund - AIF) សម្រាប់ផ្តល់ហិរញ្ញប្បទានដល់គម្រោងវិនិយោគ ដែលមានលក្ខណៈជាការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តអាស៊ាន និងជាកត្តាគន្លឹះសម្រាប់ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍ និងសម្រាប់ធានានូវភាពជោគជ័យនៃសមាហរណកម្មអាស៊ានផងដែរ។ យើងសូមវាយតម្លៃខ្ពស់ចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត រួមទាំងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (Asian Infrastructure Investment Bank - AIIB) ផង ក្នុងគោលដៅកៀរគរហិរញ្ញប្បទានបន្ថែមដល់ប្រទេសជាសមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

១៥- នៅក្នុងឱកាសដ៏វិសេសវិសាលនេះដែរ តាងនាមឱ្យរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានប្តេជ្ញាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍកម្ពុជាក្នុងគ្រប់កាលៈទេសៈ។ កិច្ចសហប្រតិបត្តិការពីធនាគារអភិវឌ្ឍន៍អាស៊ីនេះ បានចូលរួមចំណែកយ៉ាងធំធេងដល់ការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ធនាគារអភិវឌ្ឍន៍អាស៊ីនឹងបន្តផ្តល់កិច្ចសហប្រតិបត្តិការដល់កម្ពុជាដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

១៦- ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរដល់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់**, ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិទាំងអស់ សូមទទួលបាននូវសុខភាពល្អ កម្លាំងពលំមាំមួន និងសម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច និងសូមគោរពជូនពរឲ្យកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបាន

នូវជោគជ័យដ៏ត្រចះត្រចង់ បន្ថែមទៀត និងសូមឱ្យវេទិកាពិភាក្សាកម្រិតជាន់ខ្ពស់នាពេលព្រឹកនេះ ប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា តាមការរំពឹងទុក។

១៧- ជាថ្មីម្តងទៀត សូមអង្គពិធីទាំងមូល អបអរសាទរចំពោះខួបឆ្នាំទី ៥០ នៃការបង្កើតធនាគារអភិវឌ្ឍន៍អាស៊ី ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ !